# គន្លឹះនិងឥរិយាបថផ្សេងៗដែរត្រូវធ្វើនៅពេលរញ្ជួយដី

행정안전부
Ministry of the Interior and Safety
여성가족부
Ministry of Gender Equality and Family
한국건강가정진흥원
KOREAN INSTITUTE FOR HEALTHY FAMILY

នៅពេលមានការរញ្ជួយដីកើតឡើងប្រសិនបើអ្នកគ្មានឱកាសមរម្យក្នុងការវិនិច្ឆ័យនោះទេអ្នកគ្រាន់តែអនុវត្តតាមវិធីងាយៗ ដែរមាននៅក្នុងអត្ថបទខាងក្រោមទាំងនេះ។

## នៅពេលកំពុងមានការរញ្ជួយដីកើតឡើង ?



នៅពេលកំពុងមានការរញ្ជួយដីកើតឡើងសូមចូលក្រោមតុដើម្បីការពារខ្លួនហើយចាប់ជើងតុអោយជាប់។

## នៅពេលរញ្ជួយដីបានបញ្ឈប់ ?




នៅពេលរញ្ជួយដីបានបញ្ឈប់ត្រូវបិទអគ្គិសនីនិងហ្គាស, បើកទ្វារដើម្បីជានាច្រកចេញ។

## នៅពេលចេញទៅក្រៅអគារ ?



នៅពេលចេញទៅក្រៅអគារ ត្រូវធ្វើដំណើរតាមជណ្តើរ អោយលឿនបំផុត។
( ហាមធ្វើដំណើរតាមជណ្តើរយន្ត )

※ ប្រសិនបើអ្នកនៅក្នុងជណ្តើរយន្តត្រូវរហ័សចុចប៊ូតុង ហើយប្រញាប់ចុះចេញពីជណ្តើរ។

## ពេលចេញផុតអគារដល់ខាងក្រៅ ?



ពេលចេញផុតអគារដល់ខាងក្រៅ ត្រូវការពារក្បាលរបស់អ្នកដោយយកកាបូបឬដៃមកបាំង,ហើយសង្កេតមើលអគារនិងដងផ្លូវជុំវិញខ្លួន បន្ទាប់មកធ្វើការជម្លៀសខ្លួន។

## ពេលរកកន្លែងជម្លៀសខ្លួន ?




ត្រូវប្រុងប្រយ័ត្ន វត្ថុផ្សេងៗដែរធ្លាក់ពីលើ ហើយប្រញាប់ប្រញ៉ាល់ទៅកាន់ទីវាល ឬ ឧទ្យាន-ល-ដែលជាកន្លែងធំទូលាយ ដើម្បីជម្លៀសខ្លួន។
( ហាមបើកបរ )

## ពេលមកដល់កន្លែងជម្លៀសខ្លួន ?




ស្តាប់វិទ្យុឬស្ថាប័នផ្សព្វផ្សាយសាធារណៈដើម្បីទទួលបានព័ត៌មានដ៏ត្រឹមត្រូវ ហើយធ្វើតាមការណែនាំ។

# ឥរិយាបថដែលត្រូវធ្វើពេលរញ្ជួយដី នៅកន្លែងផ្សេងៗ

នៅពេលមានការរញ្ជួយដីកើតឡើងប្រសិនបើអ្នកគ្មានឱកាសមរម្យក្នុងការវិនិច្ឆ័យនោះទេអ្នកគ្រាន់តែអនុវត្តតាមវិធីងាយៗ ដែរមាននៅក្នុងអត្ថបទខាងក្រោមទាំងនេះ។

행정안전부
Ministry of the Interior and Safety
여성가족부
Ministry of Gender Equality and Family
한국건강가정진흥원
KOREAN INSTITUTE FOR HEALTHY FAMILY

## ប្រសិនបើអ្នកនៅក្នុងផ្ទះរបស់អ្នក:



សូមចូលទៅក្រោមតុដែលមាំដើម្បីការពារខ្លួនហើយចាប់ជើងតុអោយជាប់។នៅពេលដែរការរញ្ជួយដីបញ្ឈប់ត្រូវបិទអគ្គិសនីនិងហ្គាស,បើកទ្វារដើម្បីជានាច្រកចេញ ហើយរត់ចេញមកខាងក្រៅ។

## ប្រសិនបើអ្នកនៅខាងក្រៅផ្ទះ:



ត្រូវប្រុងប្រយ័ត្នរបស់ដែរធ្លាក់ពីលើហើយការពារក្បាលរបស់អ្នកដោយយកកាបូបឬដៃបាំង។សង្កេតមើលអគារនិងដងផ្លូវជុំវិញខ្លួនហើយប្រញាប់ រត់ទៅកាន់ទីវាលធំ ឬឧទ្យាន-ល-កន្លែងធំទូលាយដើម្បីជម្លៀសខ្លួន។

## ប្រសិនបើអ្នកនៅក្នុងជណ្ដើរយន្ត:



ប្រសិនបើអ្នកនៅក្នុងជណ្តើរយន្ត ត្រូវរហ័សចុចប៊ូតុង ហើយប្រញាប់ចុះចេញពីជណ្តើរ យន្តរួចធ្វើដំណើរតាមជណ្តើរធម្មតា។

※នៅពេលមានរញ្ជួយដីហាមផ្តាច់ការប្រើប្រាស់ជណ្តើរយន្ត។

## ប្រសិនបើអ្នកនៅក្នុងសាលា:



ត្រូវចូលក្រោមតុរៀន ហើយចាប់ជើងតុអោយជាប់។ នៅពេលដែរឈប់រញ្ជួយដីត្រូវធ្វើតាមការណែនាំ ហើយ រត់ចេញទៅទីវាលដើម្បីជម្លៀសខ្លួន។

## ប្រសិនបើអ្នកនៅក្នុងផ្សារទំនើបឬម៉ាត:



ត្រូវប្រុងប្រយ័ត្នរបស់ដែរធ្លាក់ពីលើពេលកំពុងរញ្ជួយដី. ការពារខ្លួនរបស់អ្នកហើយដើរទៅកាន់ជណ្តើរឬសសរធំៗដែរនៅក្បែរអ្នក។នៅពេលឈប់រញ្ជួយដីត្រូវរត់ចេញមកខាងក្រៅដើម្បីជម្លៀសខ្លួន។

## ប្រសិនបើអ្នកនៅក្នុងរោងកុនឬពហុកីឡដ្ឋាន:




ការពារខ្លួនរបស់អ្នកដោយយកកាបូបឬទ្រព្យសម្បត្តិ, វត្ថុផ្សេងៗមកការពារ ហើយចាំរហូតដល់ឈប់រញ្ជួយដី បន្ទាប់មកធ្វើតាមការណែនាំដើម្បីជម្លៀសខ្លួន។

## រសិនបើអ្នកកំពុងជិះរថភ្លើង:



ចៀសវាងការដួលបង្ករអោយមានរបួស ត្រូវចាប់ឬតោងអោយជាប់។ នៅពេលរថភ្លើងឈប់ អ្នកត្រូវធ្វើតាមការណែនាំ។

## ប្រសិនបើអ្នកកំពុងបើកបរ:




ត្រូវបន្ថយល្បឿន ហើយបើភ្លើងស៊ីញ៉ូគ្រាមានអាសន្ន បន្ទាប់មកចតឡានទៅខាងស្តាំម, វិទ្យុតាមដាន ព័ត៍មានរីឯសោរឡានមិនត្រូវដកចេញពីនោះទេ បន្ទាប់មកធ្វើការជម្លៀសខ្លួន។

## រសិនបើអ្នកនៅលើភ្នំ ឬ នៅឆ្នេរសមុទ្រ:



ត្រូវប្រយ័ត្នគ្រោះថ្នាក់ការបាក់ដីឬច្រាំង ហើយប្រញាប់ទៅកាន់កន្លែងមានសុវត្ថិភាព។ នៅឆ្នេរសមុទ្រអាចនឹងមានគ្រោះថ្នាក់ដោយស៊ូណាមិ។ពេលមានសម្លេងប្រកាសអាសន្នត្រូវភៀសខ្លួនទៅទីកន្លែងខ្ពស់ជាប្រញ៉ាប់។